ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២២០/១៣-បានចាម៉ាត ខនស្រ្កាក់សិន ខូអិលធីឌី

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **សុខ ម៉ាធឿង**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន បានចាម៉ាត ខនស្រ្កាក់សិន**

អាសយដ្ឋាន ៖ ភូមិបង្រៀន ឃុំទទុង ស្រុកដងទុង ខេត្តកំពត

ទូរស័ព្ទ ៖ ០៨៨ ៣០ ៣១ ១១៩ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ ៖

- លោក អ៊ុយ ពិសិដ្ឋ ប្រធានរដ្ឋបាលក្រុមហ៊ុន

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **-សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា**

**-សហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជាប្រចាំក្រុមហ៊ុន បានចាមាត ខនស្រ្កាក់សិន**

អាសយដ្ឋាន៖ ភូមិចង្កៀងខាងកើត ឃុំទទុង ស្រុកដងទង់ ខេត្តកំពត

ទូរស័ព្ទ ៖ ០១២ ៧៣៦ ២៧០/០១៧ ២២៨ ១២៣ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

១- លោក សុខ គីន អនុប្រធានសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា

២- លោក យ៉ាន់ ធី — អគ្គលេខាសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា

៣- លោក សួ ឆ្លួញ — ហិរញ្ញិកសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា

៤- លោក ឈុន ពៅ — ប្រធានសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជាប្រចាំក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- កម្មករទាមទារឱ្យក្រុមហ៊ុនកាត់ប្រាក់វិភាគទានចូលសហព័ន្ធសហជីពកម្មករសំណង់ និង ព្រៃឈើកម្ពុជា។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួម លេខ ២១៥ មកបវ/កព ០១៣ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០១៣ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល )។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត បានទទួលលិខិតបណ្តឹងរបស់សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា ស្តីពីការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនកាត់ប្រាក់ភាគទានសហជីព ចូលសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា របស់ពួកគាត់។

បន្ទាប់ពីបានទទួលពាក្យបណ្តឹងភ្លាម មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត បានអញ្ជើញភាគីទាំងពីរ មកធ្វើការផ្សះផ្សា ប៉ុន្តែគូភាគីទាំងពីរសុំពន្យាររហូតមកដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣។ ការផ្សះផ្សានេះ មិនទទួលលទ្ធផលមិនសះជាទេ ដោយក្រុមហ៊ុមមិនព្រមឯកភាពកាត់ប្រាក់ភាគទានជូនសហជីពទេ។

ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ

២០១៣ តាមរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួម លេខ ២១៥ មកបវ/កព០១៣ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៣ វេលាម៉ោង ០២៖០០ នាទីរសៀល។ ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការ តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទដែលនៅសល់នេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០១ ចំណុចនេះ បន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។

សេចក្ដីបង្គាប់អាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ គឺជាសេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតប្រគល់សិទ្ធិ លេខ ប.ម ០២៦/០១៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ របស់លោក ភីតាយ៉ាវ៉ាត់ ជានាយកក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ខូអិលធីឌី ផ្ទេរសិទ្ធិជូន លោក អ៊ុយ ពិសិដ្ឋ តំណាងអោយក្រុមហ៊ុន ។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ខូអិលធីឌី លេខ ៧១២ ពណ.នតក ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ២០០៦។

៣- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម លេខ ២៥៩៦ ព.ដ ចុះខែកក្កដា ឆ្នាំ២០០៧។

៤- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ខូអិលធីឌី លេខ ៦៣៣៧ ពណ.ចបក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១។

៥- កំណត់ហេតុនៃផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ខូអិលធីឌី ចុះថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ២០១៣។

៦- កំណត់ហេតុស្ដីពីការសាកសួរព័ត៌មានពីនិយោជក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ពីបទមិនព្រមកាត់ប្រាក់វិភាគទានសហជីព។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- សារណាវិវាទការងារ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន ខូអិលធីឌី ចុះថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ២០១៣។

៣- លក្ខន្តិកៈសហជីពកម្មករសំណង់ និងព្រៃឈើ ក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន ខូអិលធីឌី បានចុះបញ្ជិកានៅនាយកដ្ឋានវិវាទការងារ លេខ ២៧៦០ កប/វក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ។

៤- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកម្មករសំណង់ និងព្រៃឈើក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន ដែលបានចុះបញ្ជិកាលេខ ២៧៦០ កប/វក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣។

៥- លិខិតលេខ ០២៨/១៣ កប ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពកម្មករសំណង់ និងព្រៃឈើក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន ជាអង្គការវិជ្ជាជីវៈមួយរបស់កម្មករ និយោជិត ដែលបានចុះបញ្ជិកាពេញលក្ខណៈច្បាប់។

៦- ពាក្យបណ្តឹងលេខ ០០៨៥/១៣ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ របស់សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា គោរពចូលមក ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត ប្តឹងលោក អ៊ុយ ពិសិដ្ឋ ដែលជាអ្នកគ្រប់គ្រងនៅក្នុងក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន ពីបទមិនព្រមកាត់ប្រាក់ភាគទានសហជីព។

៧- លិខិតស្នើសុំកាត់ភាគទាន លេខ ០០៧៥/១៣ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣ របស់សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា គោរពជូន នាយកក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន ស្នើសុំឱ្យកាត់ប្រាក់ភាគទានពីសមាជិកសហជីពចំនួន ២០០០ រៀល ម្នាក់ក្នុងមួយខែ ជារៀងរាល់ខែ ចាប់ពីខែសីហា ឆ្នាំ២០១៣ នេះតទៅ។

៨- បញ្ជីឈ្មោះកម្មករនៅក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន យល់ព្រមឱ្យនាយកកាត់លុយភាគទានចំនួន ២០០០ រៀល ជារៀងរាល់ខែ ចូលសហជីព។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន លេខ ២១៥ មកបវ/កព០១៣ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន ចុះថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ ២០១៣។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១១០០ កប/អក/វក/លកអ. ចុះថ្ងៃទី១០ ខែ តុលា ឆ្នាំ២០១៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១១០១ កប/អក/វក/លកអ. ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣។

**អង្គហេតុ ÷**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ខូល អិលធីឌី (តទៅនេះហៅថា "ក្រុមហ៊ុន បានចាម៉ាត) បានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co.២៨១៧/06E ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៦។ ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតសរុបប្រមាណជា ១២០ នាក់។
- សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា គឺជាអ្នកដាក់ពាក្យបណ្តឹងនៅក្នុងសំណុំរឿងនេះ។
- សហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ទទួលបានបញ្ជិកាសហជីពលេខ ២៧៦០ កប/វក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ដោយមានកម្មករ ឈុន ពៅ ជាប្រធាន, កម្មករ ឃ្លាំង ចន្ទី ជាអនុប្រធាន និង កម្មករ យឹម សង្ហា ជាលេខាធិការសហជីព។ សហជីពនេះ មានសមាជិកសរុបប្រមាណជា ១០០ នាក់។

**ចំណុចវិវាទទី ០១ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកកាត់ប្រាក់ភាគទានចូលសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា***

- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ឱ្យនិយោជកកាត់ប្រាក់ឈ្នួលចំនួន ២០០០ រៀល ក្នុងមួយខែ ពីសមាជិកសហជីពម្នាក់ៗ ដែលស្ម័គ្រចិត្តឱ្យនិយោជកកាត់ ដោយមានលិខិតបញ្ជាក់អនុញ្ញាត ត្រឹមត្រូវ ដើម្បីបង់ភាគទានសហជីព ជូនសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន។
- សមាជិកសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ចំនួន ៤២ នាក់ បានស្នើឱ្យសុំឱ្យនិយោជកកាត់ប្រាក់ឈ្នួលចំនួន ២០០០ រៀល ដើម្បីបង់ភាគទានសហជីព ជូនសហជីព ចាប់ពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៣ តាមរយៈលិខិតស្នើសុំកាត់ភាគទានរបស់សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣) ដែលបានដាក់ជូនទៅនិយោជកនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣។ ភាគីកម្មករនិយោជិតបានផ្តល់នូវភស្តុតាងបញ្ជាក់ពីចំនួនកម្មករនិយោជិត ដែលធ្វើការស្នើសុំឱ្យនិយោជកកាត់ប្រាក់ឈ្នួល ដើម្បីបង់ជាភាគទានសហជីពនេះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ភាគីនិយោជកមិនបានជំទាស់នឹងភស្តុតាងនេះទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កម្មករនិយោជិតធ្វើការទាមទារនេះ ដោយយោងតាមមាត្រា ១២៩ នៃ

ច្បាប់ស្តីពីការងារ និងប្រការ ៥ នៃប្រកាសលេខ ៣០៥ ។

- ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនយល់ព្រមតាមការទាមទាររបស់ភាគីកម្មករនិយោជិតទេ ដោយសម្អាងទៅលើមាត្រា ២៨១ នៃច្បាប់ស្តីពីការងារ ។
- ភាគីនិយោជកបញ្ជាក់បន្ថែមទៀតថា ពាក់ព័ន្ធនឹងការកាត់ប្រាក់ឈ្នួល ដើម្បីបង់ជាភាគទានសហជីពនេះ និយោជកនឹងអនុវត្តតាមច្បាប់ ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

**ចំណុចវិវាទទី ០១ ៖** ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកកាត់ប្រាក់ឈ្នួលចំនួន ២០០០ រៀល ក្នុងមួយខែ ពីសមាជិកសហជីពម្នាក់ៗ ដែលស្ម័គ្រចិត្តឱ្យនិយោជកកាត់ ដោយមានលិខិតបញ្ជាក់អនុញ្ញាតត្រឹមត្រូវ ដើម្បីបង់ភាគទានសហជីព ជូនសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា ក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថា តើនិយោជកមានកាតព្វកិច្ចកាត់ប្រាក់ឈ្នួលចំនួន ២០០០ រៀល ក្នុងមួយខែ ពីសមាជិកសហជីពម្នាក់ៗ ដែលស្ម័គ្រចិត្តឱ្យនិយោជកកាត់ ដោយមានលិខិតបញ្ជាក់អនុញ្ញាតត្រឹមត្រូវ ដើម្បីបង់ភាគទានសហជីព ជូនសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា ក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន ដែរ ឬទេ?

មាត្រា ២៨១ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"ត្រូវហាមឃាត់មិនឱ្យនិយោជកគ្រប់រូប ធ្វើការកាត់ប្រាក់ឈ្នួលនៃកម្មករនិយោជិតដើម្បីបង់ភាគទានសហជីព និង..."*។

មាត្រា ១២៩ កថាខ័ណ្ឌទី២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"...កម្មករនិយោជិតអាចអនុញ្ញាតឱ្យកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីពដែលខ្លួនជាសមាជិក ។ ការអនុញ្ញាតនេះត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងអាចបដិសេធវិញបានគ្រប់ពេលវេលា"*។

បន្ថែមលើមាត្រា ១២៩ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ដែលបានលើកឡើងខាងលើនេះ ប្រការ ៥ កថាខណ្ឌទី៥ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិ ក្នុងការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចែងថា ៖ *"កម្មករនិយោជិតទាំងអស់ដែលជាសមាជិកសហជីព អាចស្នើសុំជាលាយលក្ខណ៍អក្សរក្នុងរយៈពេលយ៉ាងតិច ១៥ថ្ងៃមុន ដើម្បីឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីព ដែលខ្លួនជាសមាជិកស្របតាមមាត្រា ១២៩ នៃច្បាប់ស្តីពីការងារ ហើយនិយោជកត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវតាមសំណើនេះ"* ។

ផ្អែកតាមច្បាប់ និងប្រកាសខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវបានហាមឃាត់មិនឱ្យកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដើម្បីបង់ភាគទានសហជីពទេ។ ទោះជាយ៉ាងនេះក៏ដោយ ក្នុងករណីដែលមានការស្នើសុំជាលាយលក្ខណ៍អក្សរ ទៅកាន់និយោជក (ដែលត្រូវដាក់ជូននិយោជកក្នុងរយៈពេល ១៥ ថ្ងៃ មុនថ្ងៃបើកប្រាក់ឈ្នួលនៃខែ) ពីសំណាក់កម្មករនិយោជិតដែលជាសមាជិកសហជីព ដែលបានស្ម័គ្រចិត្តឱ្យ

និយោជកកាត់ប្រាក់ឈ្នួល ដើម្បីបង់ភាគទានជូនសហជីព នោះតាមច្បាប់និយោជកត្រូវចាត់ចែងពិនិត្យ និងរៀបចំកាត់ប្រាក់ឈ្នួល ដើម្បីបង់ភាគទានជូនសហជីព។ ច្បាប់ការងារ និងប្រកាសខាងលើ ក៏បានបើកសិទ្ធិឱ្យកម្មករនិយោជិត ដែលជាសមាជិកសហជីពធ្វើការបដិសេធគ្រប់ពេល ក្នុងករណីដែលកម្មករនិយោជិតមានបំណងឈប់ឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់ពួកគេ ដើម្បីបង់ភាគទានសហជីពដែរ ដោយគោរពតាមនីតិវិធីនៃការស្នើសុំឱ្យនិយោជកកាត់ប្រាក់ឈ្នួល ដើម្បីបង់ភាគទានដែរ។ ពោលគឺ ក្នុងករណីដែលកម្មករនិយោជិតមានបំណងសុំឈប់ឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់ពួកគេ ដើម្បីបង់ភាគទានសហជីព កម្មករនិយោជិតត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរទៅកាន់និយោជក។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញទៀតថា គោលបំណងនៃការតម្រូវរបស់ច្បាប់ ឱ្យមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិត ក្នុងការស្នើសុំឱ្យនិយោជកកាត់ប្រាក់ឈ្នួល ដើម្បីបង់ភាគទានសហជីព ឬក៏ស្នើសុំឱ្យនិយោជកឈប់កាត់ប្រាក់ឈ្នួល ដើម្បីបង់ភាគទានសហជីព គឺដើម្បីបង្ហាញថា ការសុំឱ្យកាត់ ឬឈប់កាត់ប្រាក់ឈ្នួលនេះ ពិតជាកើតចេញពីឆន្ទៈពិតប្រាកដរបស់កម្មករនិយោជិតមែន ពោលគឺ ដើម្បីការពារកម្មករនិយោជិតម្នាក់ៗពីការកាត់ ឬឈប់កាត់ប្រាក់ឈ្នួលរបស់គាត់ (ដោយនិយោជក) ដើម្បីបង់ភាគទានសហជីព ផ្ទុយពីឆន្ទៈរបស់ពួកគាត់ និងដើម្បីការពារនិយោជកពីកំហុសឆ្គង ក្នុងការកាត់ ឬឈប់កាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត។ ដូច្នេះ ការសុំឱ្យនិយោជកកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ដើម្បីបង់ភាគទានសហជីព ឬសុំឱ្យនិយោជកឈប់កាត់ប្រាក់ឈ្នួល ដើម្បីបង់ភាគទានសហជីព គឺត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ ដើម្បីបង្ហាញពីឆន្ទៈ និងគោលបំណងពិតប្រាកដរបស់កម្មករនិយោជិតម្នាក់ៗ ក្នុងការឱ្យនិយោជកកាត់ ឬឈប់កាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីពណាមួយ។

ម្យ៉ាងទៀត នៅក្នុងសំណុំរឿងលេខ ១៣/០៩-ជូន តិចថាយល៍ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបកស្រាយមាត្រា ១២៩ កថាខណ្ឌទី២ ខាងលើថា ៖ *"សិទ្ធិនៃការស្នើសុំកាត់ប្រាក់ឈ្នួល ឬមិនកាត់ ដើម្បីបង់ភាគទានសហជីព គឺជាសិទ្ធិផ្ដាច់មុខរបស់កម្មករនិយោជិត តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ។..."*។ *(សូមមើលបន្ថែមក្នុងសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ៤៦/១០-អ៊ី ហ្គាមេន ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី៣, លេខ ១៥/១១-ហ្គោលដេន ហ្គេនស៊ូ ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី៣ និងលេខ ១៥៤/១១- ប៊ី & អិន ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី១៦)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងមុនដែរ។

នៅក្នុងសំណុំរឿងនេះ សមាជិកសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ចំនួន ៤២ នាក់ បានស្នើឱ្យសុំឱ្យនិយោជកកាត់ប្រាក់ឈ្នួលចំនួន ២០០០ រៀល ដើម្បីបង់ជាភាគទានសហជីព ជូនសហជីពចាប់ពី ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៣ តាមរយៈលិខិតស្នើសុំកាត់ភាគទានរបស់សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣) ដែលបានដាក់ជូនទៅនិយោជកនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣។ និយោជកមិនព្រមកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដើម្បីបង់ភាគទានសហជីព

តាមការស្នើសុំនេះទេ។ ទោះជាយ៉ាងនេះក៏ដោយ ភាគីនិយោជកបានបញ្ជាក់នៅក្នុងសវនាការថា ពាក់ព័ន្ធនឹងការកាត់ប្រាក់ឈ្នួល ដើម្បីបង់ជាភាគទានសហជីពនេះ និយោជកនឹងអនុវត្តតាមច្បាប់។ ហេតុនេះ តាមរយៈការបកស្រាយខាងលើ និយោជកត្រូវមានកាតព្វកិច្ចក្នុងការកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលជាសមាជិកសហជីព ដែលស្ម័គ្រចិត្តឱ្យនិយោជកកាត់ ដោយមានលិខិតបញ្ជាក់អនុញ្ញាតត្រឹមត្រូវ ដើម្បីបង់ភាគទានសហជីព។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកកាត់ប្រាក់ឈ្នួលចំនួន ២០០០ រៀល ក្នុងមួយខែ ពីសមាជិកសហជីពម្នាក់ៗ ដែលស្ម័គ្រចិត្តឱ្យនិយោជកកាត់ ដោយមានលិខិតបញ្ជាក់អនុញ្ញាតត្រឹមត្រូវ ដើម្បីបង់ភាគទានសហជីព ជូនសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទ៖**

បង្គាប់ឱ្យនិយោជកកាត់ប្រាក់ឈ្នួលចំនួន ២០០០ រៀល ក្នុងមួយខែ ពីសមាជិកសហជីពម្នាក់ៗ ដែលស្ម័គ្រចិត្តឱ្យនិយោជកកាត់ ដោយមានលិខិតបញ្ជាក់អនុញ្ញាតត្រឹមត្រូវ ដើម្បីបង់ភាគទានសហជីព ជូនសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន។

**ប្រភេទនៃសេចក្តីបង្គាប់៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក៖**

ឈ្មោះ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា៖ ----------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត៖**

ឈ្មោះ៖ **អន ណាន**

ហត្ថលេខា៖ ----------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល៖**

ឈ្មោះ៖ **សុខ ម៉ាឌឿន**

ហត្ថលេខា៖ ----------------------------

THE ARBITRATION COUNCIL